00848686

E233

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 25 / 09 / 2012
ម៉ោង (Time/Heure) : 14:55
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១២

**ជូនចំពោះ:** ភាគីនៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** សេចក្តីណែនាំទៅភាគីក្រោយសវនាការថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២

បន្ទាប់ពីមានសវនាការដែលបានធ្វើកាលពីថ្ងៃ សុក្រ ទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូង សូមជូនដំណឹងទៅភាគីថា៖

១. សក្ខីកម្មរបស់អ្នកជំនាញឈ្មោះ Philip SHORT ដែលកាលពីដំបូងត្រូវបានគ្រោងធ្វើនៅថ្ងៃ ច័ន្ទ ទី ០១ ខែ តុលា ឆ្នាំ ២០១២ ត្រូវបានពន្យារពេល។ ជាមួយគ្នានេះ អង្គជំនុំជម្រះក៏បានសម្រេចថាសក្ខីកម្មរបស់អ្នកជំនាញឈ្មោះ Elizabeth BECKER ដែលបានគ្រោងធ្វើនៅចុងខែ តុលា ឆ្នាំ ២០១២ នេះ ក៏នឹងត្រូវពន្យារពេលដែរ។ អង្គជំនុំជម្រះនឹងចេញសេចក្តីណែនាំបន្ថែមពាក់ព័ន្ធនឹងការស្តាប់សក្ខីកម្មរបស់អ្នកជំនាញទាំង០២ រូបនេះ នាពេលសមស្របខាងមុខ។

00848687

E233

២. នាពេលដ៏ខ្លីខាងមុខ អង្គជំនុំជម្រះនឹងផ្ញើនូវរបាយការណ៍វេជ្ជសាស្ត្រទាំងអស់ដែលអង្គជំនុំជម្រះបានទទួលពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ចាប់តាំងពីពេលដែលជនជាប់ចោទ អៀង សារី បានចូលសម្រាកព្យាបាលចាប់ពីថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១២ បន្ថែមពីលើប្រតិចារឹកនៃសវនាការថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ជូនដល់សាស្ត្រាចារ្យ A. John CAMPBELL ដែលជាអ្នកជំនាញខាងជំងឺមនុស្សចាស់ដែលអង្គជំនុំជម្រះបានតែងតាំងកន្លងមក។ អង្គជំនុំជម្រះនឹងស្នើសុំយោបល់ពីសាស្ត្រាចារ្យ CAMPBELL ថាតើត្រូវធ្វើកោសល្យវិច្ឆ័យវេជ្ជសាស្ត្របន្ថែមដែរ ឬយ៉ាងណាទាក់ទិននឹងជនជាប់ចោទ អៀង សារី ក្នុងករណីចាំបាច់។

៣. អង្គជំនុំជម្រះសាលាដំបូងបានកំណត់កាលបរិច្ឆេទនៃការបង្ហាញឯកសារ ដែលភាគីនីមួយៗយល់ឃើញថាជាឯកសារពាក់ព័ន្ធបំផុតទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល (ប្រសិនបើភាគីយល់ថា ជាឯកសារចាំបាច់ និងមានភាពពាក់ព័ន្ធ) ដែលនឹងគ្រោងធ្វើនៅថ្ងៃ ច័ន្ទ ទី ០៨ ខែ តុលា ឆ្នាំ ២០១២ (សូមមើលខាងក្រោមបន្ថែម)។ អង្គជំនុំជម្រះទុកពេលវេលាចំនួន ០១ ថ្ងៃកន្លះសម្រាប់សហព្រះរាជអាជ្ញា និងកន្លះថ្ងៃសម្រាប់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីបង្ហាញឯកសាររបស់ខ្លួន។ អង្គជំនុំជម្រះទុកពេលវេលាចំនួន ០២ ថ្ងៃសម្រាប់ក្រុមមេធាវីការពារក្តីទាំងអស់ដើម្បីបង្ហាញឯកសាររបស់ខ្លួន ហើយចំណែកការបែងចែកពេលវេលាគឺអាស្រ័យទៅលើការឯកភាពគ្នាក្នុងចំណោមក្រុមមេធាវីការពារក្តីទាំងអស់។ ពេលវេលាដែលបែងចែកទុកសម្រាប់មេធាវីការពារក្តីនេះគិតបញ្ចូលទាំងឱកាសរបស់ជនជាប់ចោទក្នុងការធ្វើសេចក្តីអត្ថាធិប្បាយតាមការស្នើសុំទៅលើឯកសារណាមួយដែលត្រូវបានបង្ហាញ ឬដែលត្រូវបានដាក់រួចហើយនៅចំពោះមុខអង្គជំនុំជម្រះក្នុងអំឡុងពេលសវនាការក្នុងដំណាក់កាលនេះ។ ដូចដែលបានលើកឡើង អង្គជំនុំជម្រះនឹងទុកឱកាសឲ្យជនជាប់ចោទ អៀង សារី នាពេលបន្ទាប់មកទៀត ដើម្បីពិនិត្យឯកសារនានាដែលត្រូវបានបង្ហាញនៅក្នុងសវនាការនេះ ប្រសិនបើមានសំណើសុំ។ ក្នុងអំឡុងសវនាការទាំងនេះ អង្គជំនុំជម្រះក៏អាចបង្ហាញឯកសារខ្លះដែលពាក់ព័ន្ធទៅនឹងចំណុចអង្គហេតុទាំងនេះផងដែរ។ អង្គជំនុំជម្រះសូមអរគុណាទុកជាមុន ប្រសិនបើភាគីអាចចងក្រងជាបញ្ជីមួយដែលផ្ទុកនូវរាល់ឯកសារទាំងអស់ដែលភាគីមានបំណងបង្ហាញ នៅក្នុងអំឡុងសវនាការទាំងនេះ និងចែកឯកសារទាំងនេះជូនអង្គជំនុំជម្រះ និងភាគីផ្សេងៗឲ្យបានឆាប់តាមលទ្ធភាពដែលអាចធ្វើទៅបាន។ សវនាការបន្ថែមពាក់ព័ន្ធនឹងឯកសារក៏នឹងត្រូវកំណត់កាលបរិច្ឆេទនាពេលឆាប់ៗផងដែរ។ សេចក្តីណែនាំទៅភាគីពាក់ព័ន្ធនឹងសវនាការទាំងនេះនឹងមាននៅពេលដ៏ខ្លីខាងមុខ។

៤. នៅពេលសក្ខីកម្មរបស់សាក្សីដែលមានរហស្សនាម TCW-475 (ដែលបានគ្រោងធ្វើនៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២) បញ្ចប់ទៅ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយ ដែលមេធាវីការពារជនជាប់ចោទ អៀង សារី បានចេញលិខិតលះបង់សិទ្ធិ។ នៅថ្ងៃច័ន្ទ ទី ០១ ខែ តុលា ឆ្នាំ ២០១២ សវនាការនឹងចាប់ផ្តើមជាមួយការស្តាប់សក្ខីកម្មសាក្សីមួយរូបទៀតដែលមានរហស្សនាម TCW-320 ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល។

៥. អង្គជំនុំជម្រះសូមជូនដំណឹងទៅភាគីថាបុគ្គលខាងក្រោមនេះ នឹងត្រូវអង្គជំនុំជម្រះស្តាប់សក្ខីកម្មស្តីពីចំណុចអង្គហេតុដែលត្រូវធ្វើសវនាការពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធា៖

TCW-428
TCW-754
TCW-100
TCW-110

៦. ដោយហេតុថាសាក្សីដែលមានរហស្សនាម TCW-428 ត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីឈ្មោះរបស់បុគ្គលចំនួន ០៨ រូប ដែលមេធាវីការពារជនជាប់ចោទ អៀង សារី បានបញ្ជាក់អំពីការលះបង់សិទ្ធិ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះបន្ទាប់ពីសាក្សីដែលមានរហស្សនាម TCW-320 បានផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះរួច។ ដោយផ្អែកតាមការព្យាករណ៍នាពេលបច្ចុប្បន្ននេះ នៅពេលសក្ខីកម្មរបស់សាក្សីដែលមានរហស្សនាម TCW-428 បញ្ចប់ទៅនោះ សវនាការលើឯកសារខាងលើ (កថាខណ្ឌ ៣) នឹងប្រព្រឹត្តទៅនៅរង្វង់ថ្ងៃ ច័ន្ទ ទី ០៨ ខែ តុលា ឆ្នាំ ២០១២។

៧. អង្គជំនុំជម្រះសូមអរគុណទុកជាមុន ប្រសិនបើមេធាវីការពារជនជាប់ចោទ អៀង សារី អាចគូសបញ្ជាក់ថាតើខ្លួនត្រៀមចេញលិខិតលះបង់សិទ្ធិ ទាក់ទិននឹងសាក្សីដែលមានរហស្សនាម TCW-754, TCW-100 និង TCW-110 ដែរ ឬយ៉ាងណា។ សេចក្តីណែនាំពាក់ព័ន្ធនឹងការស្តាប់សក្ខីកម្មរបស់បុគ្គលទាំងអស់ដែលសេសសល់ក្នុងបញ្ជីខាងលើ នឹងមាននាពេលសមស្របខាងមុខ។

៨. ទាក់ទិននឹងបុគ្គលផ្សេងៗដែលមេធាវីការពារជនជាប់ចោទ អៀង សារី បានចេញលិខិតលះបង់សិទ្ធិ អង្គជំនុំជម្រះសូមជូនដំណឹងថាដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-186 នាពេលបច្ចុប្បន្នពុំមានវត្តមានឡើយ និងត្រូវបានលើកពេលស្តាប់សក្ខីកម្ម។ អង្គជំនុំជម្រះក៏នឹងបញ្ជាក់នាពេលសមស្របខាងមុខថាតើ បុគ្គលចំនួន ០៤ រូបដែលនៅសេសសល់ដែលមេធាវីការពារជនជាប់ចោទ

អៀង សារី បានចេញលិខិតលះបង់សិទ្ធិរួចហើយ នឹងផ្តល់សក្ខីកម្មនៅពេលណា ប្រសិនបើអង្គជំនុំជម្រះសម្រេចស្តាប់សក្ខីកម្មរបស់អ្នកទាំងនេះ។

៩. នាពេលដ៏ខ្លីខាងមុខ អង្គជំនុំជម្រះសាលាដំបូងក៏នឹងជូនដំណឹងទៅភាគីថាតើបុគ្គលណាខ្លះ ដែលខ្លួននឹងស្តាប់សក្ខីកម្មសម្រាប់ចំណុចអង្គហេតុដែលត្រូវធ្វើសវនាការពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន។ នៅពេលបញ្ជីនេះត្រូវបានផ្ញើទៅភាគី មេធាវីការពារជនជាប់ចោទ អៀង សារី និងសហព្រះរាជអាជ្ញាបានយល់ព្រមពិនិត្យបញ្ជីឈ្មោះ ហើយមេធាវីការពារជនជាប់ចោទ អៀង សារី នឹងអាចព្រមព្រៀងបញ្ជាក់ថាតើបុគ្គលណាខ្លះក្នុងចំណោមបុគ្គលទាំងនេះដែលខ្លួននឹងត្រៀមចេញលិខិតលះបង់សិទ្ធិ។ នៅពេលបុគ្គលទាំងឡាយដែលជាកម្មវត្ថុនៃការលះបង់សិទ្ធិត្រូវបានកំណត់អត្តសញ្ញាណរួចហើយ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មរបស់ពួកគាត់តាមលំដាប់លំដោយ ដែលនឹងត្រូវកំណត់នៅពេលក្រោយទៀត។